គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

# សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១០

## អភិបាលកិច្ចថ្នាក់មូលដ្ឋានក្នុងប្រទេសកម្ពុជា កាន់តែមានភាពល្អប្រសើរ

### ការសិក្សា បង្ហាញពីទស្សនៈរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចថ្នាក់មូលដ្ឋាន និងផលប៉ះពាល់នៃមូលនិធិឃុំ សង្កាត់

លទ្ធផលនៃការសិក្សារយៈពេល២ឆ្នាំទៅលើដំណើការអភិបាលកិច្ចថ្នាក់មូលដ្ឋាន លទ្ធផល និងទស្សនៈរបស់ប្រជាពលរដ្ឋ អំពីគណនេយ្យភាព និងការឆ្លើយតប បង្ហាញថា អភិបាលកិច្ចថ្នាក់មូលដ្ឋានកាន់តែមានភាពល្អប្រសើរ (កើនឡើង១១ភាគរយនៃសន្ទស្សន៍អភិបាលកិច្ចថ្នាក់មូលដ្ឋាន) ពីការអង្កេតជាមូលដ្ឋានឆ្នាំ២០០៨។ រីឯមូលនិធិវិនិយោគឃុំ សង្កាត់រួមចំណែកយ៉ាងសំខាន់ទៅក្នុងការធ្វើអោយប្រសើរឡើងអភិបាលកិច្ចថ្នាក់មូលដ្ឋាន។ ឧទាហរណ៍ ការសិក្សាបានរកឃើញថា ការកើនឡើងមូលនិធិឃុំសង្កាត់១០ភាគរយ ធ្វើអោយសន្ទស្សន៍អភិបាលកិច្ចថ្នាក់មូលដ្ឋានកើនឡើង ០.៩ភាគរយដែរ។

ការសិក្សានេះបង្ហាញថា ទស្សនៈរបស់ប្រជាពលរដ្ឋទៅលើតម្លាភាពរបស់ក្រុមប្រឹក្សាឃុំសង្កាត់កាន់តែខ្ពស់ នៅឃុំ សង្កាត់ណាដែលស្មៀនឃុំ សង្កាត់មានការអប់រំខ្ពស់ និងមានបទពិសោធច្រើន ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានបទពិសោធច្រើន និងនៅឃុំ សង្កាត់ណាដែលក្រុមប្រឹក្សាឃុំ សង្កាត់ អនុវត្តតាមគោលការណ៍នៃនាំបានត្រឹមត្រូវ។

ទស្សនៈរបស់ប្រជាពលរដ្ឋទៅលើក្រុមប្រឹក្សាឃុំសង្កាត់អំពីការកំណត់តម្រូវការជាអាទិភាពកាន់តែខ្ពស់ នៅឃុំសង្កាត់ដែលគម្រោងរបស់ឃុំ សង្កាត់ និងការចំណាយសរុបរយៈពេលបីឆ្នាំ កាន់តែមានទំហំធំ និងនៅឃុំ សង្កាត់ណាដែលប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មានការអប់រំច្រើន និងមានបទពិសោធការងារ។

ការសិក្សានេះក៏បានបង្ហាញផងដែរថា ពាក្យ"គណនេយ្យភាព" មិនសូវមានការយល់ដឹងទូលំទូលាយ និងត្រឹមត្រូវប៉ុន្មានទេក្នុងបរិបទកម្ពុជា។ ការណ៍នេះ ធ្វើអោយមានការលំបាកក្នុងកាប្រើប្រាស់ពាក្យ"គណនេយ្យភាព"សម្រាប់ជាសូចនាករវាស់វែងអភិបាលកិច្ចថ្នាក់មូលដ្ឋាន។ ការសិក្សាបានបង្ហាញទៀតថា យន្តការគណនេយ្យភាព (ផ្ទាំងរូបភាពគណនេយ្យភាព និងប្រអប់សំបុត្រគណនេយ្យភាពមិនសូវមានប្រសិទ្ធភាព។

ទាក់ទងទៅនឹងការចូលរួម និងសម្លេងរបស់ប្រជាពលរដ្ឋនៅក្នុងកិច្ចការក្រុមប្រឹក្សាឃុំ សង្កាត់ ការសិក្សាបានបង្ហាញថា មានប្រជាពលរដ្ឋតែ៥២ភាគរយប៉ុណ្ណោះ ចូលរួមនៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (តែតិចជាងនេះនៅតាមតំបន់ទីប្រជុំជន)។

**ឯកឧត្តម សក់ សេដ្ឋា** រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប នៅក្នុងពិធីបើកសិក្ខាសាលា បានធ្វើការកត់សម្គាល់ថា "ការសិក្សានេះ ផ្តល់អោយយើងនូវចំណេះដឹងថ្មីៗ និងព័ត៌មានដ៏មានប្រយោជន៍ ដែលជួយអោយយើងកែតម្រូវទៅលើចំណុចខ្វះខាត និងជួយអោយយើងត្រួតពិនិត្យ ទៅលើភាពរីកចំរើននៅក្នុងការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ និងអភិបាលកិច្ចថ្នាក់មូលដ្ឋាន។

នៅចុងបញ្ចប់នៃសិក្ខាសាលា **ឯកឧត្តម លេង វី** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋាននៃ គ.ជ.អ.ប ក៏បានលើកឡើងផងដែរពីការប្តេជ្ញាចិត្តបន្ថែមទៀតលើការងារធ្វើអោយប្រសើរឡើងនៃអភិបាលកិច្ចថ្នាក់ក្រោម។ **ឯកឧត្តម** បានបន្ថែមដោយស្នើយោបល់អោយមានការសិក្សាបែបនេះបន្ថែមទៀតដើម្បីផ្តល់ជាព័ត៌មាន និងការនែនាំដល់ការងារអភិបាលកិច្ចថ្នាក់មូលដ្ឋាន និងការងារអភិវឌ្ឍន៍។

ការអង្កេតជាមូលដ្ឋានឆ្នាំ២០០៨ និងការតាមដានបន្តលើការអង្កេតឆ្នាំ២០០៩ ស្តីពីទស្សនៈរបស់ប្រជាពលរដ្ឋអំពី គណនេយ្យភាព និងការឆ្លើយតប ត្រូវបានធ្វើនៅក្នុងខេត្តចំនួន៥ ដោយក្រុមហ៊ុនស្រាវជ្រាវ និងអភិវឌ្ឍន៍ SBK។ រីឯការសិក្សាវាយតម្លៃលើដំណើរការ និងការត្រួតពិនិត្យលទ្ធផល ត្រូវបានធ្វើនៅខេត្តចំនួន៣ ដោយក្រុមហ៊ុន Catalyst Management Services របស់ប្រទេសឥណ្ឌា និងវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា។ ការសិក្សាទាំងនេះបានទទួលការឧត្តមដោយគម្រោងគាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) របស់ UNDP Sida និង DFID។

***ព័ត៌មានបន្ថែមសូមធ្វើការទំនាក់ទំនង លោក ផែន រស្មី មន្ត្រីព័ត៌មាន និងទំនាក់ទំនងសាធារណៈនៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) តាមរយៈ raksmey.phen@ncdd.gov.kh ឬតាមរយៈលេខទូរសព្ទ ០១៧ ៧៩៥ ៦២៣។***